# ព្រះនេត្រព្រះ/ក្រឡាញ់/ពួក A1, A3 & A4i



| | | |
|---|---|---|
| **ខេត្ត** | : | បន្ទាយមានជ័យ និង សៀមរាប |
| **ស្រុក** | : | ក្រឡាញ់ ពួក និង ព្រះនេត្រព្រះ |
| **ផ្ទៃដី ( ហិកតា)** | : | ៦៩.៥៧០ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៤ ដល់ ១២ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១៣°២៦´ជ ១០៣°២៦´ក |

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះស្ថិតនៅទិសពាយ័ព្យនៃបឹងទន្លេសាប រួមមានតំបន់វាលស្មៅលិចទឹកតាមរដូវកាលយ៉ាងធំល្វឹងល្វើយ និង ព្រៃគុម្ពោត ។ តំបន់នេះរួមបញ្ចូលទាំងតំបន់ IBA ស្ថិតនៅប៉ែកអគ្នេយ៍ដែលជាតំបន់មួយគេបានរាយការណ៍ថា គ្របដណ្ដប់ដោយប្រភេទស្រូវស្រងែ (Wild Rice *Oryza rufipogon*) ស្ថិតនៅក្នុងព្រៃគុម្ពោតខ្ពស់ៗ និង ព្រៃលិចទឹកស្រដៀងគ្នាទៅនឹងតំបន់វាលស្រងែដែរ (KH020) ដែលគេបានរកឃើញ ។ នាឆ្នាំថ្មីៗនេះ ទីជំរកទាំងនេះត្រូវបានគេប្រែក្លាយទៅជាតំបន់ស្រូវបណ្ដេញទឹក និង ស្រូវវស្សាកាន់តែច្រើនឡើងៗ ដែលបានធ្វើឱ្យទីជំរកសំខាន់ៗក្នុងតំបន់នេះថយចុះ និង កាតផ្ដាច់ពីគ្នា ។ តំបន់នេះគឺជាកន្លែងពងកូនយ៉ាងសំខាន់របស់សត្វខ្សឹបនៅក្នុងរដូវប្រាំង ដែលមាននៅគ្រប់ទីកន្លែងនៃតំបន់វាលស្មៅលិចទឹកតាមរដូវកាល ។ ជាងនេះទៀតប្រភេទសត្វស្លាបទទួលរងការគំរាមកំហែង និង ជិតរងគ្រោះក្នុងពិភពលោកត្រូវបានកត់ត្រាពីតំបន់នេះក្នុងចំនួនតិចតួច ដូចជាក្រៀល អង្កត់ខ្មៅ និង ទុងប្រផេះ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ក្រៀល | Sarus Crane | *Grus antigone* | A1 | A4i |
| ខ្សឹប | Bengal Florican | *Houbaropsis bengalensis* | A1 | |
| ត្រយ៉ងខ្លួន ស | Black-headed Ibis | *Threskiornis melanocephalus* | A1 | |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 | A4i |
| រនាលពណ៌ | Painted Stork | *Mycteria leucocephala* | A1 | A4i |
| ស្មោញ | Darter | *Anhinga melanogaster* | A1 | |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |
| អង្កត់ខ្មៅ | Black-necked Stork | *Ephippiorhynchus asiaticus* | A1 | |

### ប្រភេទសត្វប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស (សូមមើលតារាងឧប សម្ព័ន្ធ៤) ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការប្រមាញ់សត្វស្លាបទឹក និង សត្វខ្សឹប ដោយការប្រើប្រាស់ថ្នាំពុល និង ការទាក់ចាប់ គឺជាការគំរាមកំហែងមួយនៅតែកើតមានឡើងក្នុងតំបន់នេះដែលសត្វទាំងនោះភាគច្រើនត្រូវបានគេយកមកលក់នៅតាមទីផ្សារក្នុងមូលដ្ឋានរបស់ពួកគាត់ ។ នៅក្នុងរដូវវស្សា ទំនងជាប្រជាពលរដ្ឋទាក់ចាប់សត្វស្លាបទឹកធំៗដោយសន្ទូចបង្កៃ ហើយការគំរាមកំហែងនាពេលថ្មីៗនេះដែលធ្វើឱ្យមានការព្រួយបារម្ភនោះគឺជាការប្រែក្លាយតំបន់វាលស្មៅទៅជាដីធ្វើស្រូវឡើងទឹកនៅប៉ែកអគ្នេយ៍ខេត្តបន្ទាយមានជ័យ និងប៉ែកខាងកើតខេត្តសៀមរាប ។ បញ្ហានេះកំពុងតែធ្វើឱ្យថយចុះយ៉ាងខ្លាំងនូវប្រភេទទីជំរកសម្រាប់សត្វខ្សឹប ។ ការរំខានដោយសារសកម្មភាពនៃការធ្វើកសិកម្ម (ឧទាហរណ៍ ការភ្ជួររាស់) និង ការឃ្វាលគោក្របីទាំងហ្វូងៗអាចជាការកាត់បន្ថយនៃការទទួលបានជោគជ័យក្នុងការពងកូនរបស់សត្វខ្សឹប ។ ក្មេងតូចៗប្រើប្រាស់ជំពាមកៅស៊ូ ដើម្បីបាញ់បង្អើល ឬ បាញ់សំលាប់សត្វស្លាបនៅពេលដែលពួកគេកំពុងឃ្វាលគោ ។

**អនុសាសន៍**

សកម្មភាពអនុវត្តច្បាប់ និង សកម្មភាពផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ គួរតែផ្តួចផ្តើមធ្វើឡើងដោយផ្អែកលើគំរូនៅតំបន់ស្ទឹងសែន / សន្ទុក / បារ៉ាយណ៍ (KH021) ។ ការងារនេះគួរផ្តោតលើការត្រួតពិនិត្យការបរបាញ់ និង ការធ្វើពាណិជ្ជកម្មនៃប្រភេទសត្វសំខាន់ៗ ជាពិសេសខ្សឹប ព្រមទាំងសត្វស្លាបទឹកធំៗ និង លើផលប្រយោជន៍ដែលមានសក្តានុពលដល់ប្រជាពលរដ្ឋមូលដ្ឋាន ។

ការសិក្សាស្រាវជ្រាវបន្ថែមគួរអនុវត្តលើមុខងាររបស់អេកូឡូស៊ីដែលមានទំនាក់ទំនងគ្នានៃតំបន់វាលស្មៅលិចទឹកតាមរដូវកាល និង តាមតំបន់ស្រូវឡើងទឹក ជាពិសេសតំបន់អភិរក្សសត្វខ្សឹប ។

ការអភិវឌ្ឍន៍ផ្នែកកសិកម្មបន្ថែមទៀតណាមួយ ជាពិសេស ការពង្រីកតំបន់ស្រូវឡើងទឹកមិនគួរអនុវត្តដោយមិនមានធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានពេញលេញជាមុនទេនោះ និង ការយល់ដឹងឱ្យបានត្រឹមត្រូវដោយផ្អែកលើបញ្ហាខាងលើដែលជាផលប៉ះពាល់នៃការប្រែក្លាយប្រព័ន្ធអេកូឡូស៊ីពាក់កណ្តាលធម្មជាតិទៅជាតំបន់កសិកម្ម។

**ឯកសារយោង**

Pech Bunnat (2002) *Field survey of eastern Tonle Sap in Siem Reap and Banteay Meanchey provinces*. Unpublished report to the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.